**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៨១៣...០២២...០០៤ ប្រកាសព័ត៌មាន

*ថ្ងៃសុក្រ ៣រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២*

# សេចក្តីប្រកាសព័ត៌មាន
# សិក្ខាសាលាស្តីពី ការផ្សព្វផ្សាយរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុឆ្នាំ២០២១

នៅថ្ងៃសុក្រ ៣រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ធនាគារជាតិនៃកម្ពុជាបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី របាយការណ៍ស្ថិរភាពហិរញ្ញវត្ថុឆ្នាំ២០២១ នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ ក្រោមអធិបតីភាពរបស់លោកជំទាវបណ្ឌិត ជា សិរី ឧបការីទេសាភិបាលនិងជាអគ្គនាយកបច្ចេកទេសធនាគារជាតិនៃកម្ពុជា និងមានការចូលរួមពីអាជ្ញាធរក្នុងវិស័យហិរញ្ញវត្ថុ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដៃគូអភិវឌ្ឍន៍ មជ្ឈមណ្ឌលស្រាវជ្រាវ និងសាកលវិទ្យាល័យនានា សរុបប្រមាណជាង ២០០នាក់។

សិក្ខាសាលាផ្សព្វផ្សាយនេះ មានគោលបំណងលើកកម្ពស់ការយល់ដឹងរបស់ភាគីពាក់ព័ន្ធ និងសាធារណជនឱ្យកាន់តែទូលំទូលាយអំពីវឌ្ឍនភាព ហានិភ័យនានា និងការអនុវត្តគោលនយោបាយក្នុងវិស័យហិរញ្ញវត្ថុ ព្រមទាំងទស្សនវិស័យចំពោះស្ថានភាពស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជា។ របាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ ត្រូវបានចេញផ្សាយជាសាធារណៈចាប់តាំងពីឆ្នាំ២០១៩ មក និងត្រូវបានពង្រឹងគុណភាព ស្របតាមការរីកចម្រើននៃវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្តង់ដារវិភាគអន្តរជាតិដោយមានជំនួយបច្ចេកទេសរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ។

របាយការណ៍ស្ថិរភាពហិរញ្ញវត្ថុឆ្នាំ២០២១នេះ បែងចែកជា ៤ជំពូក រួមមាន៖ i/-ស្ថានភាពនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ii/-ស្ថានភាពនិងស្ថិរភាពប្រព័ន្ធធនាគារ iii/-វិស័យហិរញ្ញវត្ថុមិនមែនធនាគារ និង iv/-ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់។ ជំពូកទី១ បង្ហាញអំពីការអភិវឌ្ឍនិងហានិភ័យចម្បងៗទាំងនៅវិស័យខាងក្រៅ (ដូចជា សេដ្ឋកិច្ចពិភពលោក ស្ថិតិជញ្ជីងទូទាត់កម្ពុជា និងការប្រែប្រួលអត្រាប្តូរប្រាក់) និងសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក (រួមមាន កំណើនសេដ្ឋកិច្ច អតិផរណា ស្ថានភាពរូបិយវត្ថុនិងសារពើពន្ធ ជាដើម)។ ចំណែកឯជំពូកទី២ បានរំលេចអំពីសូចនាករសំខាន់ៗនៅក្នុងវិស័យធនាគារ ដែលរួមមាន ធនាគារពាណិជ្ជ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារឯកទេស។ ទន្ទឹមនេះ ការរីកចម្រើនក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមមាន ទីផ្សារហិរញ្ញវត្ថុ និងវិស័យធានារ៉ាប់រង ត្រូវបានរៀបរាប់នៅក្នុងជំពូកទី៣។ ដោយឡែក ជំពូកទី៤ ដែលជាផ្នែកថ្មីមួយសម្រាប់របាយការណ៍ឆ្នាំនេះ បានបង្ហាញពីការអភិវឌ្ឍនៅក្នុងប្រព័ន្ធទូទាត់សងប្រាក់កម្ពុជា ជាពិសេសការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ដែលបានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។/.

អត្ថបទទាំងស្រុងនៃរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុនេះ ត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់ធនាគារជាតិនៃកម្ពុជា ព្រមទាំងត្រូវបានបោះពុម្ពផងដែរ។៚


**ទំនាក់ទំនង ៖**

ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា

ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦

អ៊ីម៉ែល ៖ nbccommunication@nbc.org.kh


**បណ្ដាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**

www.nbc.org.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA